FARMER NOTES

ព្រឹត្តិប័ត្រព័ត៌មានកសិករ



ការបោះពុម្ពផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute

# មូសផ្លុងលើដំណាំស្រូវ

## ១-លក្ខណៈទូទៅនៃមូសផ្លុង និងការបំផ្លាញរបស់វា



មូសផ្លុងជាសត្វល្អិតដែលមានរូបរាងតូច ដូចសត្វមូសធម្មតាដែរ។ ចំពោះមូសផ្លុងឈ្មោលពេញវ័យ ខ្លួនរបស់វាមានពណ៌លឿងត្នោត និងមានខ្លួនតូចជាងមូសផ្លុងញី ដែលមានពោះពណ៌ក្រហម។



នៅពេលភ្លៀងចាប់ផ្តើមធ្លាក់នាដើមរដូវវស្សា មូសផ្លុងពេញវ័យហើរចេញពីស្មៅចង្រៃមករកជម្រកថ្មី ដែលមានចំណី និងអាចបន្តពូជបាន។ ចំពោះមូសផ្លុងញីនិមួយៗអាចពងបានពី ១-៤ពង នៅលើស្លឹកស្រូវ និងមានជីវិតត្រឹមតែ ៤ - ៥ ថ្ងៃប៉ុណ្ណោះ ប៉ុន្តែចាប់ពីពេលពេញវ័យ រហូតដល់ងាប់ទៅវិញ វាអាចពងបានរាប់រយងណោះ។



ដង្កូវមូសផ្លុងដែលញាស់ចេញពីពង មានពណ៌សស្រអាប់ ហើយចូលលាក់ខ្លួននៅក្នុងដើមស្រូវ និងស៊ីបំផ្លាញគល់នៃបណ្តូលស្រូវ ដែលជាហេតុធ្វើឱ្យបណ្តូលស្រូវចេញមកមូលដូចផ្លុង និងពុំអាចចេញក្តួរ។ ការបំផ្លាញរបស់វាមានចាប់តាំងពីនៅថ្នាលសំណាបរហូតដល់ចុង បញ្ចប់នៃដំណាក់កាលបែកគុម្ព ។ នៅក្នុងប្រទេសកម្ពុជាយើង មូសផ្លុង មិនត្រូវបានគេចាត់ទុកជាសត្វល្អិតចង្រៃធ្ងន់ធ្ងរទេ។ មានខេត្តមួយចំនួនដែលទទួលរងនូវការបំផ្លិចបំផ្លាញគួរឱ្យកត់សំគាល់នោះមាន ដូចជាខេត្តស្វាយរៀង ព្រៃវែង កំពត និងកំពង់ចាម។

## ២-វិធានការការពារ



*ការបំផ្លាញរុក្ខជាតិទាំងឡាយជាជម្រក* : ធ្វើការកាប់ឆ្ការសំអាតស្មៅចង្រៃឬ ស្រងែ ដែលនៅជុំវិញបរិវេណស្រែ និងក្នុងស្រែ នៅពេលដាំដុះ និងក្រោយពេល ប្រមូលផល។

*ភ្ជួរស្រែបន្ទាប់ពីប្រមូលផល* : ធ្វើដីឱ្យស្អាតល្អកុំឱ្យមានរុក្ខជាតិជម្រក បន្ទាប់ពីច្រូតកាត់រួច។

*ពេលវេលាដាំដុះ* : ត្រូវពន្យាពេលដាំដុះក្នុងរដូវវស្សាឱ្យបានសមស្រប បើអាចធ្វើទៅបាន គឺធ្វើលើពូជស្រូវប្រកាន់រដូវ ដើម្បីកាត់បន្ថយវគ្គលូតលាស់របស់ស្រូវឱ្យនៅខ្លី។ ផ្ទុយទៅវិញ ធ្វើការដាំដុះពូជស្រូវមិនប្រកាន់រដូវ ឱ្យបានឆាប់របោះនៅពេលដើមរដូវវស្សា ដើម្បីឱ្យដំណាំស្រូវបានបញ្ចប់វគ្គលូតលាស់មុនពេលមូសផ្លុងផ្លាស់ទីមកពីរុក្ខជាតិជម្រកជាការប្រសើរ។



*ជៀសវាងការដាំដុះបន្តបន្ទាប់គ្នាឥតដាច់:* ត្រូវដាំដុះកុំឱ្យយឺតជាងស្រែជិតខាង ៣សប្តាហ៍។

*ការដាក់ជី:* ការប្រើប្រាស់ជីអ៊ុយរ៉េក្នុងកម្រិតមធ្យម ហើយត្រូវបាចវាបីលើក (ដំណាក់កាលសំណាប , បែកគុម្ព និងកំណកំណើតកួរ ) ជាវិធីដ៏ល្អក្នុងការការពារជាមួយមូសផ្លុង ដែលមានការបំផ្លាញ និងរាតត្បាត ។

*ដំណាំបង្វិល* : ការដាំស្រូវបន្តគ្នារហូត អាចធ្វើឱ្យប្រជាកររបស់មូសផ្លុងកើនឡើង។ ផ្ទុយទៅវិញការទុកដីស្រែនៅទំនេរ ឬការអនុវត្តន៍ការដាំដំណាំបង្វិលដោយការថែទាំមិនឱ្យមានស្មៅ អាចកាត់បន្ថយប្រជាករមូសផ្លុងបានដែរ។

*ការប្រើប្រាស់ពូជធន់* : ការដាំដុះពូជធន់ គឺជាវិធានការមួយប្រកបដោយប្រសិទ្ធភាពល្អបំផុតក្នុងការការពារពីការបំផ្លាញរបស់មូសផ្លុង។ ការពិសោធន៍តាមដានពូជស្រូវធន់ទ្រាំទៅនឹងការបំផ្លាញរបស់មូសផ្លុងកំពុងតែប្រព្រឹត្តទៅនៅក្នុងប្រទេសកម្ពុជា។ តាមលទ្ធផលពិសោធន៍ដំបូងខាងលើនេះ គឺមានពូជប្រពៃណីកម្ពុជាមួយចំនួនដូចជា ***ឈុត្តនា នាងមិញ*** និង ***សូម៉ាលី*** ហើយនិងពូជស្រូវទំនើបដូចជា **អ៊ីអ៊ែរ៦៦ អ៊ីអ៊ែរ៤២** មានភាពធន់ទៅនឹងការបំផ្លាញរបស់មូសផ្លុង។

## ៣-ការកម្ចាត់

ការបាញ់ថ្នាំសម្លាប់សត្វល្អិតប្រភេទពុលខ្លាំង ដើម្បីកម្ចាត់ប្រភេទសត្វល្អិតចង្រៃណាមួយ អាចធ្វើឱ្យមានការរាតត្បាតដោយមូសផ្លុងកាន់តែខ្លាំងឡើងថែមទៀត។ថ្នាំនោះបានសម្លាប់ពពួកសត្វល្អិតមានប្រយោជន៍ ដូចជា ពីងពាង ពួក ឪម៉ាល់ និង ប៉ារ៉ាស៊ីត ដែលជាសត្រូវធម្មជាតិសម្រាប់ការសម្លាប់មូសផ្លុង។ ការកម្ចាត់មូសផ្លុងដោយប្រើថ្នាំសម្លាប់សត្វល្អិតមានការលំបាកជាទីបំផុត ព្រោះដង្កូវមូសផ្លុងរស់នៅក្នុងដើមស្រូវ។ ប្រភេទថ្នាំសម្លាប់សត្វល្អិតជ្រាបចូល ដែលមានប្រសិទ្ធិភាពខ្ពស់ក្នុងការកម្ចាត់មូសផ្លុងនោះ គឺមានតែថ្នាំ វីដែន ឬ ហ្វ៊ីប្រូនីលមួយគត់នៅក្នុងប្រទេសកម្ពុជា។ ថ្នាំនេះមានទម្រង់ពីរយ៉ាង មួយជាគ្រាប់ និងមួយទៀតជាទឹក។ ថ្នាំហ្វ៊ីប្រូនីលទម្រង់ជាគ្រាប់មានប្រសិទ្ធិភាពខ្ពស់ក្នុងការកម្ចាត់មូសផ្លុងជាងប្រភេទថ្នាំទឹក បើសិនជានៅក្នុងស្រែនោះមានទឹកជាអចិន្ត្រៃយ៍។ ការប្រើថ្នាំគ្រាប់ហ្វ៊ីប្រូនីលលើថ្នាលសំណាបមុននឹងយកទៅស្ទូង ក្នុងរយៈ ពេលពី ១ ទៅ ២ សប្តាហ៍អាចការពារការបំផ្លាញធ្ងន់ធ្ងរពីមូសផ្លុងបាន។ សរុបមក មុនពេលសម្រេចចិត្តប្រើប្រាស់ថ្នាំគីមីនេះ ត្រូវគិតទៅដល់សេដ្ឋកិច្ច បរិស្ថាន និងសុខភាព ជាមុនសិនថាតើគួរប្រើ ឬមិនគួរ ហើយត្រូវកំណត់ឲ្យបានច្បាស់ជៀសវាង ការប្រើទាំងប្រថុយប្រថាន។